| |
|---|
| តុលាការខេត្ត<br>សៀមរាប-ឧត្ដរមានជ័យ<br>__សាលក្រម__<br>លេខ ១២៨ ខ ចុះថ្ងៃទី ០២<br>ខែ តុលា ឆ្នាំ ២០០៦<br>__សំណុំរឿងរដ្ឋប្បវេណី__<br>លេខ ៣៩៣ ចុះថ្ងៃទី ២៩<br>ខែ កញ្ញា ឆ្នាំ ២០០៦ |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### នាមប្រជារាស្ត្រខ្មែរ
### តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប នាថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

__ចៅក្រមជំនុំជំរះ__

លោក [redacted] ប្រធានតុលាការខេត្ត

__តំណាងអយ្យការ__

លោក [redacted] ព្រះរាជអាជ្ញាអមតុលាការខេត្ត

__ក្រឡាបញ្ជីសវនាការ__

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះសំណុំរឿងក្ដីរដ្ឋប្បវេណីលេខ ៣៩៣ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៦ ដែលមានកម្មវត្ថុបណ្ដឹង __ប្ដឹងសុំសិទ្ធិទទួលមរតក__ ។

រវាងដើមចោទអ្នកស្រី ម សន អាយុ ៣៤ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ ទីលំនៅ១ភូមិបឹងដូនប៉ា ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ម ធ (រ) ម្ដាយឈ្មោះ ទ ន (ស) ប្ដីឈ្មោះ ស មណ មានកូន ០៣នាក់ ។

__ដំណើររឿងមានដូចតទៅ__ :

តាមពាក្យបណ្ដឹងចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ របស់ដើមចោទអ្នកស្រី ម សន បានប្ដឹងសុំសិទ្ធិទទួលមរតកដែលបន្សល់ទុកដោយម្ដាយរបស់ខ្លួនមានដីមួយប្លង់មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ សរ ០០២៧៨២ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ "AII 0695 " ជាកម្មសិទ្ធិរបស់ខ្លួនដោយសំអាងហេតុថា ដីមួយប្លង់នោះជាកម្មសិទ្ធិរបស់ម្ដាយខ្លួន ហើយកាលពីថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៦ ម្ដាយរបស់ខ្លួនបានទទួលមរណៈភាព ដោយបន្សល់ទុកដីមួយប្លង់នោះឱ្យខ្លួនគ្រប់គ្រងជាកម្មសិទ្ធិ ។

__នាពេលសវនាការ__

ដើមចោទអ្នកស្រី ម សន បានឆ្លើយថា ខ្លួនសុំសិទ្ធិទទួលមរតកដែលបន្សល់ទុកដោយម្ដាយរបស់ខ្លួនមានដីមួយប្លង់ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ

សាលក្រមនេះចូលជាស្ថាពរចាប់ពីថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៦
ដោយភាគីទាំងអស់ពុំបានប្ដឹងឧទ្ធរណ៍ ។
សៀមរាប,ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
ហត្ថលេខា [redacted]

សរ ០០២៧៨២ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ " AII 0695 " ហើយខ្លួនទទួលខុសត្រូវសងបំណុលទាំងអស់ ដែលម្តាយខ្លួនបានជំពាក់អ្នកដទៃ ដោយសំអាងហេតុថា ដីមួយប្លង់នោះជាកម្មសិទ្ធិរបស់ម្តាយខ្លួន ហើយកាលពីថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៦ ម្តាយរបស់ខ្លួនបានទទួលមរណៈភាពដោយបន្សល់ទុកដីមួយប្លង់នោះឱ្យខ្លួន ។

អ្នកស្រី **ស សថ** និង អ្នកស្រី **ស សខ** ជាបងប្អូនបង្កើតរបស់សពឈ្មោះ **ទ ន** បានឆ្លើយថា សពឈ្មោះ **ទ ន** មានកូនបង្កើតម្នាក់ឈ្មោះ **ម សន** ។

ក្នុងរឿងនេះពួកខ្លួនយល់ព្រមប្រគល់ដីមួយប្លង់ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ សរ០០ ២៧៨២ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ " AII 0695 " ដែលជាកម្មសិទ្ធិរបស់សពឈ្មោះ **ទ ន** ឱ្យទៅឈ្មោះ **ម សន** គ្រប់គ្រងជាកម្មសិទ្ធិតទៅ ។

**<u>តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា</u>**

រឿងក្តីនេះជារឿងរដ្ឋប្បវេណី ទាក់ទិនទៅនឹងលទ្ធកម្មដោយសន្តិកម្មតាមច្បាប់ភូមិបាល ។
ហេតុនេះសូមតុលាការពិចារណាសំរេចតាមច្បាប់ ។

-បានស្តាប់ចម្លើយដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-បានស្តាប់ចម្លើយរបស់បងប្អូនសពឈ្មោះ **ទ ន**

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

**<u>តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ</u>**

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា</u>**

-ពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង ច្បាប់ ។

-ដីមួយប្លង់ស្ថិតនៅភូមិវិហារចិន ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ អចលនវត្ថុលេខ សរ ០០២៧៨២ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ " AII 0695 " ជាកម្មសិទ្ធិរបស់សពឈ្មោះ **ទ ន** ។

-ដើមចោទអ្នកស្រី **ម សន** ជាកូនទោលតែម្នាក់គត់របស់សពឈ្មោះ **ទ ន** ហើយអ្នកស្រី **ទ ន** បានទទួលមរណៈភាពកាលពីថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៦ ។

-ដើមចោទប្តឹងសុំសិទ្ធិទទួលមរតក ដែលបន្សល់ទុកដោយសពឈ្មោះ **ទ ន** មានដីមួយប្លង់ស្ថិតនៅភូមិវិហារចិន ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ សរ ០០២៧៨២ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ " AII 0695 " ហើយយល់ព្រមទទួលខុសត្រូវសងបំណុលទាំងអស់ដែលសពឈ្មោះ **ទ ន** បានជំពាក់អ្នកដទៃ ហើយបងប្អូនទាំងអស់នៃសពឈ្មោះ **ទ ន** បានយល់ព្រមដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

**<u>ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី</u>**

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-មរតកដែលបន្សល់ទុកដោយសពឈ្មោះ ខ ន មានដីមួយប្លង់ស្ថិតនៅភូមិវិហារចិន ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ សរ ០០២៧៨២ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ " AII 0675 " ត្រូវប្រគល់អោយអ្នកស្រី ម សន ជាកូនបង្កើត គ្រប់គ្រងជាកម្មសិទ្ធិតទៅ ហើយបង្គាប់ឱ្យឈ្មោះ ម សន សងបំណុលដែលសពឈ្មោះ ខ ន បាន ជំពាក់អ្នកដទៃ ។

៣-សំរេចឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ១.៨០០រ០០ រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់ ២០០រ០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រ០០ បូករួម ៧.០០០រ០០ ។ ប្រាក់ នេះបានកាត់យកពីប្រាក់ ៧.០០០រ០០ ដែលដើមចោទបានបង់ទុករួចហើយ ។

៤-សាលក្រមនេះជំនុំជំរះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី . បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់រយៈពេល ០២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

| | |
|---|---|
| ក្រឡាបញ្ជីសវនាការ | ចៅក្រមជំនុំជំរះ |
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| [redacted] | [redacted] |